# ការគាំទ្រជំនួសដែលអ្នកអាចចំណាយប្រាក់ NDIS លើវាបាន

Khmer | ភាសាខ្មែរ

## ជំនួយជាមួយនឹងឯកសារនេះ

អ្នកអាចរកនរណាម្នាក់ឲ្យជួយអ្នកបាន៖

- យល់ដឹងពីឯកសារនេះ
- ស្វែងរកព័ត៌មានបន្ថែម។

ព័ត៌មានទំនាក់ទំនងមាននៅចុងបញ្ចប់នៃឯកសារនេះ។

## អំពីឯកសារនេះ

ទីភ្នាក់ងារធានារ៉ាប់រងជនពិការថ្នាក់ជាតិ (NDIA) បានសរសេរឯកសារនេះ។

នៅពេលយើងប្រើពាក្យថាយើង វាមានន័យថា NDIA។

យើងផ្តល់គម្រោងធានារ៉ាប់រងជនពិការថ្នាក់ជាតិ (National Disability Insurance Scheme) ឬ NDIS។

ឯកសារនេះនិយាយអំពីការគាំទ្រជំនួស ដែលអ្នក**អាច**ចំណាយមូលនិធិ NDIS លើវាបាន។

# តើនៅក្នុងឯកសារនេះមានអ្វីខ្លះ?


អំពីឯកសារនេះ 2

ការគាំទ្រជំនួស 4

ការគាំទ្រនានាដែលអ្នកអាចត្រូវបានអនុញ្ញាតឱ្យចំណាយប្រាក់ NDIS លើវាបាន 4

របស់របរប្រើប្រាស់ក្នុងផ្ទះដែលជាធម្មតាមានលក់នៅទីផ្សារ 4

នាឡិកាឆ្លាតវៃ 5

ថេប្លេត 5

ទូរសព្ទស្មាតហ្វូន 5

កម្មវិធីនានាសម្រាប់ភាពងាយចូលប្រើប្រាស់ និងគោលបំណងប្រាស្រ័យទាក់ទង 6

ព័ត៌មានបន្ថែមអំពីឯកសារនេះ 6

ស្វែងយល់បន្ថែមទៀតអំពី NDIA 7

រកជំនួយដើម្បីទាក់ទងមកយើង 7

## ការគាំទ្រជំនួស

ការគាំទ្រជំនួសគឺជាការគាំទ្រដែល៖

- យើងបាននិយាយថាអ្នក មិនអាច ចំណាយប្រាក់ NDIS លើវាបានទេ
- សម្រាប់អ្នកដើម្បីប្រើប្រាស់ក្នុងករណីមួយចំនួន។

អ្នក **អាច** ត្រូវបានអនុញ្ញាតឱ្យទទួលបានការគាំទ្រជំនួស ប្រសិនបើយើងយល់ព្រម។

ការគាំទ្រជំនួសត្រូវតែ៖

- ជំនួសការគាំទ្រមួយដែលមាននៅក្នុងផែនការរបស់អ្នក
- ថ្លៃចំណាយដូចគ្នា ឬតិចជាងការគាំទ្រនៅក្នុងផែនការរបស់អ្នក
- ដូចគ្នា ឬល្អសម្រាប់អ្នកជាងការគាំទ្រនៅក្នុងផែនការរបស់អ្នក។

## ការគាំទ្រនានាដែលអ្នកអាចត្រូវបានអនុញ្ញាតឱ្យចំណាយប្រាក់ NDIS លើវាបាន

## របស់របរប្រើប្រាស់ក្នុងផ្ទះដែលជាធម្មតាមានលក់នៅទីផ្សារ

នេះមានន័យថាអ្វីទាំងឡាយសម្រាប់គេហដ្ឋានដែលត្រូវបានបញ្ជាក់ថាវាអាចជួយ៖

- ចំពោះតម្រូវការនៃអ្នកមានពិការភាព
- ឲ្យអ្នកមានភាពឯករាជ្យ។

មនុស្សមួយចំនួនអាចចំណាយប្រាក់ NDIS លើបច្ចេកវិទ្យាជំនួយបាន។

បច្ចេកវិទ្យាជំនួយមានន័យថាអ្វីទាំងឡាយដែលជួយជនពិការ។

## នាឡិកាឆ្លាតវៃ

នាឡិកាឆ្លាតវៃគឺជាអ្វីមួយដែល៖

- ភ្ជាប់ទៅនឹងអ៊ីនធឺណិត
- អ្នកអាចពាក់នៅលើកដៃរបស់អ្នកបាន។

អ្នកអាច ត្រូវបានអនុញ្ញាតឱ្យចំណាយប្រាក់ NDIS លើនាឡិកាឆ្លាតវៃមួយប្រសិនបើវា៖

- ជួយអ្នកក្នុងការប្រាស្រ័យទាក់ទង
- គឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់អ្នកប្រាស្រ័យទាក់ទង។

## ថេប្លេត

ថេប្លេតគឺជាអ្វីមួយដែល៖

- ភ្ជាប់ទៅនឹងអ៊ីនធឺណិត
- អ្នកអាចយកវាទៅណាជាមួយអ្នកបាន។

អ្នកអាច ត្រូវបានអនុញ្ញាតឱ្យចំណាយប្រាក់ NDIS លើថេប្លេតមួយប្រសិនបើវា៖

- ជួយអ្នកក្នុងការប្រាស្រ័យទាក់ទង
- គឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់អ្នកប្រាស្រ័យទាក់ទង។

## ទូរសព្ទស្មាតហ្វូន

ទូរសព្ទស្មាតហ្វូនគឺជាអ្វីមួយដែល៖

- ភ្ជាប់ទៅនឹងអ៊ីនធឺណិត
- អ្នកអាចយកវាទៅណាជាមួយអ្នកបាន។

អ្នកអាច ត្រូវបានអនុញ្ញាតឱ្យចំណាយប្រាក់ NDIS លើទូរសព្ទស្មាតហ្វូនមួយគ្រឿង ប្រសិនបើវា៖

- ជួយអ្នកក្នុងការប្រាស្រ័យទាក់ទង
- គឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់អ្នកប្រាស្រ័យទាក់ទង។

## កម្មវិធីនានាសម្រាប់ភាពងាយចូលប្រើប្រាស់ និងគោលបំណងប្រាស្រ័យទាក់ទង

កម្មវិធីនានាសម្រាប់ភាពងាយចូលប្រើប្រាស់ និងគោលបំណងប្រាស្រ័យទាក់ទងគឺជា កម្មវិធីនានាដែល៖

- អ្នកដាក់ឱ្យដំណើរការក្នុងអ្វីមួយ ដូចជាថេប្លេត
- ជួយអ្នកក្នុងការប្រាស្រ័យទាក់ទង។

អ្នកអាច ត្រូវបានអនុញ្ញាតឱ្យចំណាយប្រាក់ NDIS លើកម្មវិធីនានា ប្រសិនបើកម្មវិធីទាំងនោះ៖

- ជួយអ្នកក្នុងការប្រាស្រ័យទាក់ទង
- គឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់អ្នកក្នុងការប្រាស្រ័យទាក់ទង។

## ព័ត៌មានបន្ថែមអំពីឯកសារនេះ

សម្រាប់ព័ត៌មានបន្ថែមអំពីឯកសារនេះ សូមទាក់ទងមកយើង។

អ្នកអាចហៅទូរសព្ទមកយើងបាន **1800 800 110**

អ្នកអាចផ្ញើអ៊ីមែលមកយើង **enquiries@ndis.gov.au**

អ្នកអាចមកកាន់ការិយាល័យរបស់យើងផ្ទាល់បាន

អ្នកអាចរកមើលការិយាល័យក្នុងតំបន់របស់អ្នកនៅលើគេហទំព័រ NDIS **ndis.gov.au/contact/locations**

## ស្វែងយល់បន្ថែមទៀតអំពី NDIA

ចូលមើលគេហទំព័ររបស់យើង ndis.gov.au

តាមដានយើងនៅលើបណ្តាញសង្គមរបស់យើង

Facebook, Twitter, Instagram, YouTube, LinkedIn

## រកជំនួយដើម្បីទាក់ទងមកយើង

សម្រាប់អ្នកដែលត្រូវការជំនួយជាភាសាអង់គ្លេស

អ្នកអាចហៅទូរសព្ទទៅសេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)។ **131 450**

សម្រាប់មនុស្សថ្លង់ ឬពិបាកស្តាប់

សេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ (National Relay Service)៖ relayservice.gov.au

អ្នកអាចប្រើមុខងារទូរសព្ទជាអក្សរ (TTY)បាន។ **1800 555 677**

អ្នកអាចប្រើការបញ្ជូនបន្តជាសំឡេងបាន។ **1800 555 727**